01002565

E305/15

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 24 / 07 / 2014
ម៉ោង (Time/Heure): 15:25
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

**អនុស្សរណៈ- អង្គជំនុំជម្រះសាលាដំបូង** **សាធារណៈ / Public**

ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១៤

**ជូនចំពោះ:** **ភាគីទាំងអស់នៃសំណុំរឿង ០០២**

**ពី:** Matteo CRIPPA **មន្ត្រីច្បាប់នៃអង្គជំនុំជម្រះសាលាដំបូង**

**ចម្លងជូន:** **លោក/លោកស្រីចៅក្រម និងមន្ត្រីច្បាប់ជាន់ខ្ពស់ នៃអង្គជំនុំជម្រះសាលាដំបូង**

**កម្មវត្ថុ:** **រហស្សនាមថ្មីសម្រាប់សាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ ដែលបានស្នើសុំឲ្យមកផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿង ០០២/០២**

១. ពាក់ព័ន្ធទៅនឹងការបើកសវនាការបឋមបន្ថែមក្នុងសំណុំរឿង ០០២/០២ និងការរៀបចំបើកសវនាការដេញដោលលើភ័ស្តុតាងនៅក្នុងសំណុំរឿង ០០២/០២ អង្គជំនុំជម្រះសាលាដំបូងចេញនូវបញ្ជីឈ្មោះសម្ងាត់ដែលមានរហស្សនាមថ្មីរបស់សាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ ទាំងអស់ដែលបានស្នើសុំដោយភាគីកាលពីពេលកន្លងទៅដើម្បីឱ្យមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ។

២. អង្គជំនុំជម្រះសាលាដំបូងសូមរម្លឹកដល់ភាគីទាំងអស់ថា លើកលែងតែមានការបញ្ជាក់ផ្សេងពីនេះ ភាគីត្រូវប្រើរហស្សនាមរបស់សាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និង អ្នកជំនាញ ឬតាមរយៈមធ្យោបាយសមស្របផ្សេងទៀត នៅក្នុងសវនាការជាសាធារណៈ និងនៅក្នុងសារណានានាមុនពេលអ្នកទាំងនោះចូលមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ។